# បញ្ជីសេវាកម្មរបស់ Harbor Regional Center

ខែធ្នូ ឆ្នាំ 2024

HARBOR
REGIONAL CENTER



**ការគិតគូរសំខាន់ៗ៖**

- ធនធានទូទៅគួរតែត្រូវបានស្រាវជ្រាវ តាមការសមរម្យ
- បញ្ជីនេះមិនលម្អិតពេញលេញទេ
- សេវាកម្មគឺផ្អែកលើតម្រូវការរបស់បុគ្គល ហើយគួរតែពិភាក្សាជាមួយអ្នកសម្របសម្រួលសេវាកម្ម

| សេវាកម្ម | អាយុ 0-3 | អាយុចូលរៀន | មនុស្សធំ | ការពិពណ៌នាអំពីសេវាកម្ម |
|---|---|---|---|---|
| ការបណ្ដុះបណ្ដាលអំពីជំនាញសម្របខ្លួន | | ✓ | ✓ | ដោះស្រាយបណ្ដុំជំនាញ ដូចជា ការចូលរួមក្នុងសង្គម ការទំនាក់ទំនង អនាម័យផ្ទាល់ខ្លួន ការជួយខ្លួនឯង និងសមាហរណកម្មចូលក្នុងសហគមន៍ ។ សេវាកម្មត្រូវបានរៀបចំឡើងដើម្បីបង្រៀនបុគ្គលដែលទទួលសេវា ឲ្យមានភាពឯករាជ្យម្ចាស់ការតាមអាយុ ស្របតាមសកម្មភាពរស់នៅប្រចាំថ្ងៃ នៅពេលដែលតម្រូវការទាំងនេះមិនបានសម្រេចតាមរយៈមណ្ឌលសិក្សាធិការ ។ ការចូលរួមរបស់អ្នកមើលថែ ត្រូវបានគេណែនាំជាសំខាន់ ។ ដោយផ្អែកលើតម្រូវការដែលបានវាយតម្លៃ សេវាកម្មនានាអាចត្រូវបានគេផ្ដល់ឲ្យជាលក្ខណៈក្រុម/បុគ្គល ។ |
| កម្មវិធីសម្រាប់សកម្មភាពនៅពេលថ្ងៃរបស់មនុស្សធំ | | | ✓ | សេវាកម្មដែលផ្ដល់ជូននូវការបម្រើកម្មវិធីពេលថ្ងៃជាច្រើនប្រភេទ ដែលផ្ដល់នូវសកម្មភាពតាមរចនាសម្ព័ន្ធ និងចម្រុះនៅក្នុងសហគមន៍សម្រាប់បុគ្គលដែលទទួលសេវា ដែលលែងមានសិទ្ធិទទួលបានសេវាកម្មរបស់សាលាទៀតហើយ ។ ជាធម្មតា បុគ្គលដែលទទួលសេវា ដែលចូលរួមក្នុងកម្មវិធីទាំងនេះ បានជ្រើសរើសមិនបន្តការសិក្សានៅថ្នាក់ឧត្ដមសិក្សា ឬរកការងារធ្វើទេ ។ |
| ការវាយតម្លៃ និងការពិគ្រោះយោបល់ | ✓ | ✓ | ✓ | សេវាកម្មដែលផ្ដល់ជូន រាប់បញ្ចូលទាំង ការសម្របសម្រួលឲ្យមានការពិគ្រោះយោបល់ជាមួយអ្នកឯកទេសម្នាក់ ឬច្រើនរបស់មជ្ឈមណ្ឌល Harbor ដើម្បីធ្វើការវាយតម្លៃពីតម្រូវការរបស់បុគ្គលដែលទទួលសេវាកម្ម ។ ការវាយតម្លៃ និងការពិគ្រោះយោបល់អាចជួយក្នុងការផ្ដល់ ឬការបញ្ជាក់លើការធ្វើរោគវិនិច្ឆ័យ ការកំណត់ពីប្រភេទសេវាកម្ម និងជំនួយដែលត្រូវការ ការកំណត់ពីតម្រូវការសុខភាពគ្រួសារ និងសុខភាពផ្លូវចិត្ត ។ល។ |

# បញ្ជីសេវាកម្មរបស់ Harbor Regional Center

ខែធ្នូ ឆ្នាំ 2024

HARBOR
REGIONAL CENTER

| សេវាកម្ម | អាយុ 0-3 | អាយុចូលរៀន | មនុស្សធំ | ការពិពណ៌នាអំពីសេវាកម្ម |
|---|---|---|---|---|
| បច្ចេកវិទ្យាជំនួយ៖ ការទំនាក់ទំនងបង្កើន និងជំនួស (AAC) | ✓ | ✓ | ✓ | សេវាកម្មដែលផ្តល់ឲ្យបុគ្គលម្នាក់ដែលទទួលសេវានូវឧបករណ៍ជំនួយ ឬសម្របខ្លួនសម្រាប់គោលបំណងនៃការជួយសម្រួលដល់ចល័តភាព ការទំនាក់ទំនង និងការបង្កើនការទទួលបានសេវាពីសហគមន៍ ។ ក៏អាចរាប់បញ្ចូលឧបករណ៍វាយតម្លៃ AAC ផងដែរ ដែលប្រើប្រាស់ដោយបុគ្គលដែលទទួលសេវា ក្នុងបរិវេណមណ្ឌលសិក្សាធិការ ។ |
| សេវាកម្មខាងអាកប្បកិរិយា | ✓ | ✓ | ✓ | សេវាកម្មដែលត្រួតពិនិត្យដោយ អ្នកវិភាគខាងអាកប្បកិរិយាដែលមានការបញ្ជាក់ពីក្រុមប្រឹក្សាភិបាល (BCBA) ហើយដែលរៀបចំឡើងដើម្បីដោះស្រាយបញ្ហាប្រឈមខាងអាកប្បកិរិយា ។ ការធ្វើអន្តរាគមន៍/ការបណ្តុះបណ្តាលអាចត្រូវបានគេផ្តល់ឲ្យបុគ្គលដែលទទួលសេវា និងអ្នកមើលថែរបស់ពួកគេ ក្នុងផ្ទះ និងសហគមន៍ និងអាចជាលក្ខណៈ 1:1 ឬជាក្រុម ។ |
| សេវាកម្មថែទាំកុមារ | ✓ | ✓ | | ការថែទាំកុមារ គឺជាការមើលបុគ្គលម្នាក់ដែលទទួលសេវា ដែលមានអាយុក្រោម 18 ឆ្នាំ ដែលអ្នកមើលថែរបស់ពួកគេមិនទំនេរ ដើម្បីផ្តល់ការថែទាំ ឬមើលថែបែបនេះបាន ពីព្រោះពួកគេជាប់ធ្វើការ ឬកំពុងទទួលការបណ្តុះបណ្តាលការងារ /ការសិក្សា ។ សេវាកម្មនេះកើតឡើងក្នុងផ្ទះ ឬសហគមន៍ ក្នុងទីកន្លែងដែលមានអាជ្ញាបណ្ណ និងគ្មានអាជ្ញាបណ្ណ និងតាមរយៈអ្នកមើលថែ ដែលចាត់ចែងដោយគ្រួសារ ឬអ្នកផ្តល់សេវា ។ |
| ការបណ្តុះបណ្តាលអំពីសមាហរណកម្មចូលក្នុងសហគមន៍ | | ✓ | ✓ | សេវាកម្មទាំងនេះត្រូវបានរៀបចំដើម្បីពង្រឹងសមត្ថភាពបុគ្គលដែលទទួលសេវា ដើម្បីសម្រេចបាននូវការចូលរួមក្នុងសហគមន៍ និងសកម្មភាពនានាបានច្រើនជាងមុន ។ សេវាកម្មនេះ មាន (ជាអាទិ៍) ជំនួយក្នុងការថែទាំ ការលើកកម្ពស់ ឬការធ្វើឲ្យប្រសើរឡើងនូវការជួយខ្លួនឯង ការចូលរួមក្នុងសង្គម និងជំនាញសម្របខ្លួន ដែលកើតឡើងក្នុងកន្លែងដែលមិននៅក្នុងគេហដ្ឋាន ពោលគឺដាច់ចេញពីផ្ទះ ។ |

# បញ្ជីសេវាកម្មរបស់ Harbor Regional Center

ខែធ្នូ ឆ្នាំ 2024

HARBOR
REGIONAL CENTER

| សេវាកម្ម | អាយុ 0-3 | អាយុចូលរៀន | មនុស្សធំ | ការពិពណ៌នាអំពីសេវាកម្ម |
|---|---|---|---|---|
| សេវាកម្មជំនួយគ្រួសារដោយមានការសម្របសម្រួល (CFS) | | | ✓ | សេវាកម្មដែលរៀបចំឡើងសម្រាប់បុគ្គលដែលទទួលសេវាដែលមានអាយុចាប់ពី 18 ឆ្នាំឡើង ដែលកំពុងរស់នៅក្នុងផ្ទះរបស់គ្រួសារពួកគេ ។ ជំនួយអាចរាប់បញ្ចូលទាំង ការរៀបចំពេលណាត់ជួបពិនិត្យសុខភាព ការរកជម្រើសធ្វើដំណើរ ការបណ្តុះបណ្តាលដល់អ្នកផ្តល់សេវារបស់បុគ្គលដែលទទួលសេវា ការរៀបចំផែនការអនាគត ។ល។ សេវាកម្មទាំងនេះត្រូវបានផ្តល់ឲ្យក្នុងផ្ទះរបស់គ្រួសារ និងក្នុងសហគមន៍របស់ពួកគេ ។ ការធ្វើដូច្នេះអនុញ្ញាតឲ្យអ្នកផ្តល់សេវាធ្វើការសម្របសម្រួលសេវាកម្មដែលទូទាត់ដោយមជ្ឈមណ្ឌល Harbor និង/ឬមូលនិធិទូទៅដូចជា Medi-Cal, ធានារ៉ាប់រងឯកជន ។ល។ |
| សេវាកម្មអន្តរាគមន៍វិបត្តិ | | ✓ | ✓ | សេវាកម្មទាំងឡាយដែលរៀបចំឡើងដើម្បីបង្ការ ឬកាត់បន្ថយប្រពលភាពនៃសកម្មភាពធ្ងន់ធ្ងរ ឬដែលគំរាមកំហែងដល់ជីវិត ដែលអាចបណ្តាលឲ្យមានគ្រោះថ្នាក់ ឬគុណភាពជីវិតធ្លាក់ចុះសម្រាប់បុគ្គលដែលទទួលសេវា គ្រួសារ និង/ឬសហគមន៍របស់ពួកគេ ។ សេវាកម្មទាំងនេះមានរាប់បញ្ចូលទាំងការអភិវឌ្ឍផែនការ និងយុទ្ធសាស្ត្រសុវត្ថិភាព ដែលមានគោលបំណងក្នុងការកាត់បន្ថយតម្រូវការសម្រាប់ការប្រើប្រាស់សេវាកម្មសង្គ្រោះបន្ទាន់ ការចូលសម្រាកពេទ្យរោគចិត្ត ការចូលរួមក្នុងប្រព័ន្ធផ្លូវច្បាប់ និងតម្រូវការសម្រាប់ការប្តូរទៅកន្លែងរស់នៅដែលមានលក្ខណៈរឹតត្បិតជាងមុន ។ |
| សម្ភារៈវេជ្ជសាស្ត្រដែលប្រើបានយូរ | ✓ | ✓ | ✓ | សម្ភារៈ/ឧបករណ៍វេជ្ជសាស្ត្រសម្រាប់បុគ្គលដែលទទួលសេវា ដែលមានតម្រូវការខាងវេជ្ជសាស្ត្រ ។ សម្ភារៈផ្គត់ផ្គង់ទាំងនេះអាចមានដូចជា៖<br>• ខោទឹកនោម/ក្រដាសជូត/កម្រាលគ្រែដែលអាចោកគក់បាន<br>• សម្ភារៈផ្គត់ផ្គង់សម្រាប់ការពារភ្នែក/ត្រចៀក<br>• សម្ភារៈសម្រាប់ចល័ត (ឧ. ឈើច្រត់ និងរទេះរុញ)<br>• សម្ភារៈផ្គត់ផ្គង់សម្រាប់អាហារូបត្ថម្ភ<br>• ប្រដាប់ពាក់ដើម្បីបន្ធូរការឈឺចាប់ជើងនិងកែងជើង និងរបស់សិប្បនិម្មិត<br>• សម្ភារៈសម្រាប់សម្រួលដល់ការលើកដាក់ និងកិច្ចការដែលទាក់ទងនឹងការរស់នៅប្រចាំថ្ងៃ<br>• ការកែយានយន្ត/ផ្ទះសម្រាប់ការធ្វើដំណើរនិងចេញចូលឲ្យបានស្រួល |

# បញ្ជីសេវាកម្មរបស់ Harbor Regional Center

ខែធ្នូ ឆ្នាំ 2024

HARBOR
REGIONAL CENTER

| សេវាកម្ម | អាយុ 0-3 | អាយុចូលរៀន | មនុស្សធំ | ការពិពណ៌នាអំពីសេវាកម្ម |
|---|---|---|---|---|
| កម្មវិធីមុខរបរ | | | ✓ | សេវាកម្មទាំងឡាយដែលផ្តោតលើផ្នែកនានានៃការជួយមនុស្សធំដែលទទួលសេវាក្នុងការទទួលបាន និងរក្សាមុខរបរ ។ សេវាកម្មខាងមុខរបរ អាចរាប់បញ្ចូលដូចខាងក្រោម៖<br>• កម្មវិធីនៅពេលថ្ងៃដែលផ្តល់ជូននូវមុខរបរ និងការបណ្តុះបណ្តាល<br>• ថ្នាក់រៀនអំពីការបណ្តុះបណ្តាលការងារ<br>• សេវាកម្មមុខរបរតាមតម្រូវការ<br>• សេវាកម្មមុខរបរដោយមានការជួយទំនុកបម្រុង (ការបង្រៀនពីការងារ)<br>• សេវាកម្មពេលថ្ងៃតាមការចង់បាន<br>• មាគ៌ាអាជីពដោយមានការសម្របសម្រួល |
| ទីភ្នាក់ងារផ្តល់ជម្រកដល់ចាស់ជរា (FHA)/ទីភ្នាក់ងារផ្តល់ជម្រកដល់កុមារចិញ្ចឹម (FFA) | | ✓ | ✓ | សេវាកម្មទាំងនេះផ្តល់នូវជម្រើសក្នុងការរស់នៅជំនួសដល់បុគ្គលដែលទទួលសេវា ។ សម្រាប់កុមារ សេវាកម្មត្រូវបានផ្តល់ជូនតាមរយៈទីភ្នាក់ងារផ្តល់ជម្រកដល់កុមារចិញ្ចឹម ហើយសម្រាប់មនុស្សធំ សេវាកម្មត្រូវបានផ្តល់ជូនតាមរយៈទីភ្នាក់ងារផ្តល់ជម្រកដល់ចាស់ជរា ។ ទីភ្នាក់ងារ FFA/FHA ជួយបុគ្គលទាំងឡាយដែលទទួលសេវាលើតម្រូវការថែទាំប្រចាំថ្ងៃ ហើយឲ្យពួកគេចូលរួមក្នុងសកម្មភាពរបស់គ្រួសារពួកគេ ។ |
| ជំនួយទំនុកបម្រុងដល់គ្រួសារ | ✓ | ✓ | ✓ | ជំនួយទំនុកបម្រុងដែលផ្តល់ឲ្យគ្រួសារទាំងឡាយដើម្បីជួយបុគ្គលដែលទទួលសេវាឲ្យមានអារម្មណ៍ទទួលស្គាល់ថាជាផ្នែកមួយនៃគ្រួសារ និងសមាហរណកម្មចូលក្នុងសហគមន៍ ។ អាចរាប់បញ្ចូលទាំង ក្រុមទ្រទ្រង់ឪពុក/ម្តាយ កម្មវិធីបង្រៀនរបស់ឪពុកម្តាយដល់ឪពុកម្តាយផ្សេង ថ្នាក់បង្រៀន និងបទបង្ហាញព័ត៌មានសម្រាប់គ្រួសារទាំងឡាយដែលត្រូវបានផ្តល់ជូនពេញមួយឆ្នាំ ។ |
| មន្ទីរថែទាំសុខភាព (HCF) | ✓ | ✓ | ✓ | សេវាកម្មនានាផ្តល់ការមើលថែជំនាញ និងការថែទាំដល់អ្នកជំងឺសម្រាកព្យាបាលក្នុងមន្ទីរព្យាបាលមួយដល់បុគ្គលទាំងឡាយដែលទទួលសេវា ដែលមិនអាចរស់នៅម្នាក់ឯង ដោយសារសភាពធ្ងន់ធ្ងរនៃតម្រូវការសុខភាពរបស់ពួកគេ ។ |

# បញ្ជីសេវាកម្មរបស់ Harbor Regional Center

ខែធ្នូ ឆ្នាំ 2024

HARBOR REGIONAL CENTER

| សេវាកម្ម | អាយុ 0-3 | អាយុចូលរៀន | មនុស្សធំ | ការពិពណ៌នាអំពីសេវាកម្ម |
|---|---|---|---|---|
| ជំនួយសុខភាពតាមផ្ទះ | ✓ | ✓ | ✓ | សេវាកម្មទាំងឡាយដែលរៀបចំឡើងដើម្បីការពារសុខុមាលភាពរបស់បុគ្គលដែលទទួលសេវា ហើយបង្ការដល់ភាពចាំបាច់ក្នុងការចូលសម្រាកពេទ្យ ។ សេវាកម្មទាំងនេះអាចរាប់បញ្ចូលទាំង ការចុះសួរសុខទុក្ខតាមផ្ទះជាប្រចាំពីសំណាក់គិលានុបដ្ឋាយិកាដែលមានអាជ្ញាបណ្ណ ការត្រួតពិនិត្យនិងវាយតម្លៃ ការមើលថែទាំតាមវេន និងការបណ្តុះបណ្តាលដល់អ្នកមើលថែ ។ |
| សេវាកម្មរស់នៅដោយឯករាជ្យ (ILS) | | | ✓ | សេវាកម្មទាំងឡាយដែលរៀបចំឡើងសម្រាប់បុគ្គលដែលទទួលសេវាដែលមានអាយុចាប់ពី 18 ឆ្នាំឡើង ដែលកំពុងរស់នៅក្នុងផ្ទះគ្រួសាររបស់ពួកគេ ។ ការបណ្តុះបណ្តាលអាចរាប់បញ្ចូល តែមិនកម្រិតត្រឹមតែការធ្វើម្ហូប ការចាត់ចែងលុយកាក់ ការទទួលបានសេវាពីសហគមន៍នោះទេ ។ |
| សេវាកម្មសម្រាប់ការលូតលាស់របស់កុមារ | ✓ | | | សេវាកម្មទាំងឡាយដែលរៀបចំឡើងដើម្បីជួយដល់តម្រូវការនៃការលូតលាស់របស់បុគ្គលដែលទទួលសេវាមានអាយុចាប់ពី 0-5 ឆ្នាំ ។ កម្មវិធីទាំងនេះអាចត្រូវបានផ្តល់ជូនតាមផ្ទះ និងសហគមន៍ ជាលក្ខណៈ 1:1 ឬជាក្រុម ។ |
| ធានារ៉ាប់រង ថ្លៃទូទាត់រួមគ្នា សហធានារ៉ាប់រង និងថ្លៃរួមចំណែកពីហោប៉ៅផ្ទាល់ខ្លួន | ✓ | ✓ | ✓ | ការចេញថ្លៃចំណាយពីហោប៉ៅផ្ទាល់ខ្លួនដែលកើតឡើងពីសេវាពិនិត្យសុខភាពទូទៅ ឬធ្មេញដែលចាំបាច់ ដែលមិនមានការរ៉ាប់រងពេញលេញពីគម្រោងធានារ៉ាប់រងសុខភាពរបស់បុគ្គលដែលទទួលសេវា ឬពីប្រភពផ្តត់ផ្គង់មូលនិធិសាធារណៈផ្សេងទៀតដែលមាន ។ សិទ្ធិទទួលបានត្រូវបានកំណត់តាមរយៈការវាយតម្លៃលើប្រាក់ចំណូលគ្រួសារ ។ |

# បញ្ជីសេវាកម្មរបស់ Harbor Regional Center

ខែធ្នូ ឆ្នាំ 2024

HARBOR REGIONAL CENTER

| សេវាកម្ម | អាយុ 0-3 | អាយុចូលរៀន | មនុស្សធំ | ការពិពណ៌នាអំពីសេវាកម្ម |
|---|---|---|---|---|
| អ្នកឯកទេស និងអ្នកមានវិជ្ជាជីវៈសុខាភិបាល | ✓ | ✓ | ✓ | សេវាកម្មនានាត្រូវបានចុះកិច្ចសន្យាជាមួយអ្នកមានវិជ្ជាជីវៈសុខាភិបាលផ្សេងៗ ដើម្បីជួយផ្តល់សេវាកម្ម ជាលក្ខណៈបុគ្គល ដើម្បីកែលម្អ ឬរក្សាស្ថានភាពសុខភាពរបស់បុគ្គលដែលទទួលសេវា ។ អ្នកឯកទេស មាន (ជាអាទិ៍)៖<br>• ពេទ្យឯកទេសត្រចៀក/អ្នកឯកទេសពិនិត្យភ្នែកនិងប្រើឡង់ទី<br>• ទន្តពេទ្យ<br>• អ្នកជំនាញខាងចំណីអាហារ<br>• អ្នកប្រឹក្សាខាងហ្សែន<br>• អ្នកចិត្តវិទ្យា/គ្រូពេទ្យផ្នែកវិកលចរិត<br>• គ្រូពេទ្យ/គិលានុបដ្ឋាក/យិកា |
| ការបណ្តុះបណ្តាលអំពីចល័តភាព | | ✓ | ✓ | សេវាកម្មដែលរៀបចំដើម្បីជួយបុគ្គលទាំងឡាយដែលទទួលសេវាដែលមានអាយុចាប់ពី 18 ឆ្នាំឡើង ដើម្បីរៀនពីរបៀបប្រើប្រាស់មធ្យោបាយធ្វើដំណើរសាធារណៈក្នុងសហគមន៍របស់ពួកគេ ។ |
| ជំនួយផ្ទាល់ខ្លួន / សេវាកម្មថែទាំខ្លួន | | ✓ | ✓ | សេវាកម្មទាំងឡាយដែលចាំបាច់ដើម្បីផ្តល់ឲ្យបុគ្គលដែលទទួលសេវានូវការថែទាំ ឬការមើលដោយសមរម្យ និងផ្ទាល់ក្នុងផ្ទះ និងសហគមន៍តាមការចង់បានរបស់ពួកគេ ដោយអ្នកមើលថែម្នាក់ដែលចាត់ចែងដោយគ្រួសារ ឬដោយអ្នកផ្តល់សេវា។ នេះអាចរាប់បញ្ចូលទាំងការជួយមុជទឹក ការតុបតែងខ្លួន ការស្លៀកពាក់ ការចូលបន្ទប់ទឹក ការរៀបចំពេលបាយ និងការមើលការខុសត្រូវ ។ ជំនួយបែបនេះ អាចជួយដល់ការធ្វើសមាហរណកម្មចូលក្នុងសហគមន៍របស់បុគ្គលដែលទទួលសេវា ដែលស្ថិតក្នុងវ័យជំទង់ និងមនុស្សធំ ។ |
| សេវាកម្មខាងឱសថ | ✓ | ✓ | ✓ | សេវាកម្មទាំងឡាយដែលអនុញ្ញាតឲ្យមជ្ឈមណ្ឌលប្រចាំតំបន់ទិញថ្នាំពេទ្យសម្រាប់បុគ្គលដែលទទួលសេវា នៅពេលពួកគេមិនអាចទទួលបានធានារ៉ាប់រងថែទាំសុខភាព ឬនៅពេលថ្នាំដែលត្រូវការ ទាក់ទងនឹងពិការភាពរបស់ពួកគេ មិនត្រូវបានគ្របដណ្តប់ដោយក្រុមហ៊ុនធានារ៉ាប់រង ។ |

# បញ្ជីសេវាកម្មរបស់ Harbor Regional Center

ខែធ្នូ ឆ្នាំ 2024

HARBOR
REGIONAL CENTER

| សេវាកម្ម | អាយុ 0-3 | អាយុចូលរៀន | មនុស្សធំ | ការពិពណ៌នាអំពីសេវាកម្ម |
|---|---|---|---|---|
| មណ្ឌលថែទាំតាមបុរី | ✓ | ✓ | ✓ | មណ្ឌលថែទាំដែលមានលក្ខណៈគ្រួសារ ដែលស្ថិតក្នុងសង្កាត់នានា ដែលផ្តល់ទីកន្លែងដ៏មានសុវត្ថិភាពដល់បុគ្គលដែលទទួលសេវាដើម្បីរស់នៅរួមគ្នា ។ មណ្ឌលថែទាំទាំងនេះមានអាជ្ញាបណ្ណត្រឹមត្រូវ ដែលផ្តល់ការថែទាំ និងមើលការខុសត្រូវ 24 ម៉ោង ។ |
| សេវាកម្មសម្រាក (តាមផ្ទះ) | ✓ | ✓ | ✓ | សេវាកម្មទាំងនេះផ្តល់ការសម្រាល ឬការសម្រាកបណ្តោះអាសន្ន ពីការតម្រូវបន្ថែមដែលដាក់បន្ទុកមកលើអ្នកមើលថែរបស់បុគ្គលដែលទទួលសេវា ។ ត្រូវបានផ្តល់សេវាជូនតាមផ្ទះគ្រួសារ ឬក្នុងកន្លែងដែលមានអាជ្ញាបណ្ណត្រឹមត្រូវ និងដោយអ្នកមើលថែម្នាក់ដែលចាត់ចែងដោយគ្រួសារ ឬដោយអ្នកផ្តល់សេវា ។ ត្រូវបានសម្របសម្រួលតាមរយៈប្រភេទការសម្រាកមិនវេជ្ជសាស្ត្រ វេជ្ជសាស្ត្រ ឬខាងអាកប្បកិរិយា ។ ប្រភេទវេជ្ជសាស្ត្រទាមទារឲ្យបុគ្គលិកផ្តល់សេវាសម្រាកនោះជាអ្នកមានវិជ្ជាជីវៈសុខាភិបាលដែលមានអាជ្ញាបណ្ណត្រឹមត្រូវ ឬជានរណាម្នាក់ដែលមានការបញ្ជាក់/ទទួលបានការបណ្តុះបណ្តាលក្នុងការផ្តល់នូវកម្រិតនៃការថែទាំចាំបាច់ ។ ចំណែកឯ ប្រភេទខាងអាកប្បកិរិយាវិញតម្រូវឲ្យបុគ្គលិកផ្តល់សេវាសម្រាកមានការបណ្តុះបណ្តាលខាងបច្ចេកទេស/វិធីសាស្ត្រធ្វើអន្តរាគមន៍ខាងអាកប្បកិរិយា ។ |
| ស្វ័យសម្រេច | | ✓ | ✓ | គំរូនៃការផ្តល់ជូនសេវាមិនតាមលក្ខណៈបុរាណមួយ ដែលអនុញ្ញាតឲ្យអ្នកចូលរួមមានសេរីភាព និងការគ្រប់គ្រងលើសេវាកម្ម និងជំនួយនានាសម្រាប់បុគ្គលដែលទទួលសេវា ។ ជាមួយនឹងថវិកាបុគ្គល អ្នកចូលរួមទទួលខុសត្រូវចំពោះការកំណត់ និងការរៀបចំផែនការសម្រាប់សេវាកម្មរបស់ពួកគេសម្រាប់ឆ្នាំនោះ តាមរយៈផែនការចំណាយមួយ តាមការឯកភាព និងយល់ស្របជាមួយនឹងមជ្ឈមណ្ឌលប្រចាំតំបន់នោះ ។ |
| ការសម្របសម្រួលសេវាកម្ម | ✓ | ✓ | ✓ | សេវាកម្មដែលផ្តល់ជូនរួមមាន ការធ្វើផែនការសេវាកម្មប្រចាំខ្លួនជាបន្តជាមួយបុគ្គលដែលទទួលសេវា និងគ្រួសាររបស់ពួកគេ ។ តាមរយៈការវាយតម្លៃពីតម្រូវការ ការធ្វើផែនការរាប់បញ្ចូលទាំង ការសម្របសម្រួលជាមួយសហគមន៍ ឬធនធាននានាដែលចុះកិច្ចសន្យា ការគាំទ្រ និងការពិនិត្យមើលឡើងវិញជាប្រចាំ យ៉ាងហោចណាស់ជារៀងរាល់ឆ្នាំ ឬញឹកញាប់ជាងនេះនៅពេលមានការចាំបាច់ ។ |

# បញ្ជីសេវាកម្មរបស់ Harbor Regional Center

ខែធ្នូ ឆ្នាំ 2024

HARBOR REGIONAL CENTER

| សេវាកម្ម | អាយុ 0-3 | អាយុចូលរៀន | មនុស្សធំ | ការពិពណ៌នាអំពីសេវាកម្ម |
|---|---|---|---|---|
| ការចូលរួមក្នុងសង្គម សេវាលំហែរ និងកម្សាន្ត រាប់បញ្ចូលទាំងការព្យាបាលមិនមែនវេជ្ជសាស្រ្ត និងការសិក្សា | | ✓ | ✓ | សេវាកម្មទាំងនេះ រាប់បញ្ចូលទាំងកម្មវិធី ឬសកម្មភាពទាំងឡាយដែលលើកកម្ពស់ដល់ការធ្វើសមាហរណកម្មចូលក្នុងសហគមន៍ និងការបណ្តុះបណ្តាលលើការគាំទ្រខ្លួនឯង ដោយសារវាទាក់ទងនឹងការកម្សាន្ត និងលំហែររបស់បុគ្គលដែលទទួលសេវា ។ ការព្យាបាលមិនមែនវេជ្ជសាស្រ្ត គឺជាសេវាកម្មដែលអាចមានតម្លៃ ប៉ុន្តែមិនផ្អែកលើភស្តុតាង ។ សេវាកម្មសិក្សា គឺជាសេវាកម្មទាំងឡាយណាដែលផ្តល់ជូនជាទូទៅដោយមណ្ឌលសិក្សាធិការសម្រាប់បុគ្គលនានាតាមអាយុចូលរៀន។ |
| ការបណ្តុះបណ្តាល / ថ្នាក់បង្រៀនពីជំនាញសង្គម | | ✓ | ✓ | សេវាកម្មមួយដែលប្រើបច្ចេកទេស និងវិធីសាស្រ្តព្យាបាលខាងអាកប្បកិរិយាដើម្បីធ្វើឲ្យប្រសើរឡើងនូវជំនាញសង្គមរបស់បុគ្គលដែលទទួលសេវា នៅពេលចំណុចត្រូវការដែលបានរកឃើញ មិនបានឆ្លើយតបពេញលេញក្នុងមជ្ឈដ្ឋានផ្សេង ដូចជាសាលា / ថ្ងៃ / កម្មវិធីខាងអាកប្បកិរិយា ។ កម្មវិធីទាំងនោះគឺផ្អែកលើការស្រាវជ្រាវ មានពេលកំណត់ ហើយផ្តល់ជូនក្នុងមជ្ឈដ្ឋានជាលក្ខណៈក្រុម ។ |
| ជំនួយកម្មវិធីបន្ថែម | | ✓ | ✓ | បុគ្គលិកបន្ថែមត្រូវបានដាក់បន្ថែមទៅក្នុងប្រព័ន្ធទ្រទ្រង់ដល់បុគ្គលដែលទទួលសេវា នៅពេលពួកគេជួបវិបត្តិ ឬមានតម្រូវការជំនួយបន្ថែម ដើម្បីបន្តប្រើប្រាស់សេវាកម្មនានា ។ ជាធម្មតា សេវាកម្មទាំងនេះមានជាបណ្តោះអាសន្ន រហូតដល់បុគ្គលដែលទទួលសេវា លែងត្រូវការ ។ ជំនួយទ្រទ្រង់ទាំងនេះ អាចត្រូវបានគេប្រើដូចខាងក្រោម៖<br>• កម្មវិធីនៅពេលថ្ងៃ<br>• កម្មវិធីតាមបុរី |

# បញ្ជីសេវាកម្មរបស់ Harbor Regional Center

ខែធ្នូ ឆ្នាំ 2024

HARBOR REGIONAL CENTER

| សេវាកម្ម | អាយុ 0-3 | អាយុចូលរៀន | មនុស្សធំ | ការពិពណ៌នាអំពីសេវាកម្ម |
|---|---|---|---|---|
| សេវាកម្មទ្រទ្រង់ដល់ការរស់នៅ | | | ✓ | សេវាកម្មទាំងឡាយដែលផ្តល់ឲ្យបុគ្គលដែលទទួលសេវាដែលមានអាយុចាប់ពី 18 ឆ្នាំឡើង ដើម្បីរស់នៅក្នុងផ្ទះរបស់ពួកគេឲ្យបានឯករាជ្យម្ចាស់ការតាមដែលអាចធ្វើទៅបាន ។ សេវាកម្មនេះអាចរាប់បញ្ចូលទាំង ការចូលរួមក្នុងសកម្មភាពនានា ការកសាងទំនាក់ទំនងនៅក្នុងសហគមន៍របស់ពួកគេ ។<br>សេវាកម្មមានជាអាទិ៍៖<br>• ជំនួយក្នុងស្វែងរកផ្ទះ<br>• ការបណ្តុះបណ្តាល និងការគាំទ្រក្នុងជំនាញរស់នៅប្រចាំថ្ងៃ (ដូចជា ការរៀបចំពេលអាហារ ការធ្វើថវិកា និងការទិញ)<br>• ការផ្តល់ការឆ្លើយតបគ្រាអាសន្ន 24/7<br>• ការជ្រើសរើស និងការបណ្តុះបណ្តាលបុគ្គលដែលត្រូវផ្តល់ជំនួយ ។ |
| សេវាកម្មព្យាបាល | ✓ | ✓ | ✓ | សេវាកម្មព្យាបាលដែលផ្តល់ជូនបុគ្គលដែលទទួលសេវា មានជាអាទិ៍៖<br>• ការព្យាបាលខាងការងារឬសកម្មភាពប្រចាំថ្ងៃ<br>• ការព្យាបាលខាងរាងកាយ<br>• ការព្យាបាលខាងការនិយាយ |
| សេវាកម្មបកប្រែឯកសារ / ផ្ទាល់មាត់ | ✓ | ✓ | ✓ | មានសេវាកម្មនានាដើម្បីជួយបុគ្គលដែលទទួលសេវា និងគ្រួសាររបស់ពួកគេធ្វើការទំនាក់ទំនង និងយល់ពីឯកសារនានា នៅពេលដែលភាសាអង់គ្លេស មិនមែនជាភាសាដែលពួកគេចង់បាន ។ គេអាចផ្តល់ជូនក្នុងអំឡុងពេលកិច្ចប្រជុំធ្វើផែនការ វគ្គបណ្តុះបណ្តាល និងពេលផ្តល់សេវាកម្មជាក់ស្តែង និងក្នុងកិច្ចប្រជុំផ្សេងទៀត ។ |
| ការដឹកជញ្ជូន | ✓ | ✓ | ✓ | សេវាកម្មដែលផ្តល់លទ្ធភាពឲ្យបុគ្គលដែលទទួលសេវាអាចធ្វើដំណើរក្នុងសហគមន៍របស់ពួកគេ ដោយឯករាជ្យម្ចាស់ការ និងក្នុងតម្លៃសមរម្យបំផុតតាមដែលអាចធ្វើទៅបាន ។ ជម្រើសខ្លះក្នុងចំណោមជម្រើសទាំងនេះ មានជាអាទិ៍៖<br>• ការដឹកជញ្ជូនដែលទូទាត់ដោយសមាជិកគ្រួសារ<br>• មធ្យោបាយធ្វើដំណើរទៅពិនិត្យសុខភាព<br>• ការដឹកជញ្ជូនមិនវេជ្ជសាស្ត្រ<br>• មធ្យោបាយដឹកជញ្ជូនសាធារណៈ ដូចជា តាក់ស៊ី ឡានក្រុង ឬសេវាកម្មអាក់សេស (Access) |